Reading Boook

# ពិភពរឿងនិទាន
The World of Stories

# រឿង ទន្សាយ និង ព្រះចន្ទ
# The Rabbit and The Moon



សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

មានតំណាលថា  កាលពីព្រះពុទ្ធបរមគ្រូនៃយើងត្រាច់រង្គាត់អន្ទោលជាតិក្នុងវដ្តសង្សារនៅឡើយ។  ក្នុងជាតិមួយ  ព្រះអង្គទ្រង់យោនយកកំណើតជាសត្វទន្សាយ។



Once upon a time, when the Buddha was caught in the life cycle of birth and death and in one birth, he was born as a rabbit.





នៅរាល់ថ្ងៃពេញបូណ៌មី ទន្សាយពោធិសត្វតែងតែសមាទានរក្សាឧបោសថសីល ដោយឧទ្ទិសជីវិតព្រះអង្គជាទានបរមត្ថបារមី ដើម្បីបំពេញព្រះពោធិសម្ភារឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ។

Every full moon day, the rabbit always observed the precepts in order to devote his life to the holy metaphysics with the intention to preserve and deeply concentrate on the dharma leading to the Buddha hood.



នៅថ្ងៃពេញបូណ៌មីមួយ ព្រះឥន្ទ្រទ្រង់ជ្រាបក៏កាឡាខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់មកសុំសាច់ព្រះអង្គជាអាហារ។ ព្រះពោធិសត្វក៏សុខចិត្តបូជាជីវិតដល់ព្រាហ្មណ៍ចាស់ ប៉ុន្តែព្រាហ្មណ៍នោះទូលព្រះអង្គថា "ខ្ញុំកាន់សីលយូរណាស់មកហើយ មិនដែលសម្លាប់សត្វម្តងណាឡើយ"។



One full moon day, the Indra knew about this and he disguised himself as an old Brahman and begged for his flesh as food. The rabbit agreed to devote his life for the old Brahman. But the old Brahman said "I have practiced the precepts for a long time and I have never killed any animal".



ពេលនោះ ទន្សាយពោធិសត្វក៏បង្គាប់ឱ្យព្រាហ្មណ៍ចាស់បង្កាត់ភ្លើងឡើង ដើម្បីលោតសំលាប់ខ្លួន។ ប៉ុន្តែមុននឹងលោតចូលទៅក្នុងភ្លក់ភ្លើងនោះ ព្រះអង្គបានអធិដ្ឋានថា "សូមឱ្យព្រះឆាយលក្ខណ៍នៃព្រះអង្គទៅប្រតិស្ឋានផ្តិតជាប់នៅនឹងមណ្ឌលព្រះចន្ទ្រផង"។



Then the rabbit told the old Brahman to light fire in order for him to leap into the flames to death. But before jumping into the fire, he wished: "May my head locate in the center of the moon".



បន្ទាប់មក ព្រះពោធិសត្វក៏លោតចូលក្នុងភ្លក់ភ្លើងនោះ ដើម្បីឱ្យបានសាច់ដល់ព្រាហ្មណ៍ចាស់បរិភោគបានដូចបំណង។

After that, the rabbit jumped into the fire, so that the old Brahman could have his flash as his food as he wished.









ក្រោយមក ដោយអានុភាពនៃទានបរមត្ថបារមីនោះផង ទើបបានជារូបភាពទន្សាយមានប្រាកដនៅនឹងមណ្ឌលព្រះចន្ទ្រ ដូចដែលយើងមើលឃើញសព្វថ្ងៃនេះ។

Under the power of the Buddha, the shape of the rabbit has appeared in the center of the moon as we see nowadays.



លុះចំណេរក្រោយមក  បណ្ដាជននាំគ្នារំលឹកកំណើតសត្វទន្សាយសត្វ ពោធិសត្វនេះ ទើបធ្វើពិធីបុណ្យ "អកអំបុកសំពះព្រះខែ" គឺសំពះព្រះឆាយលក្ខណ៍ព្រះពោធិសត្វនេះឯង ដោយនាំគ្នាជ្រើសរើសចំណីអាហារជាទីគាប់ចិត្តម្រូវនឹងអធ្យាស្រ័យនៃសត្វទន្សាយមាន ចេក អំបុក ដំឡូង ដូង ត្រាវ ជាដើម យកមកឧទ្ទិសថ្វាយជាហូរហែ ជាប់ជាទំនៀមទំលាប់រហូតមកដល់ សព្វថ្ងៃនេះ។



Afterward, in order to dedicate to the birth of the rabbit, we celebrate the "Auk Ambok Sampeah Preah Khe ceremony". This ceremony is to salute the head of the rabbit .The people choose the food that is suitable for the rabbit such as bananas, pounded rice, potatoes, coconuts and taro for traditional dedications ever since.





ហេតុដូច្នេះហើយបានជាអ្នកស្រុកប្រារព្ធពិធី អកអំបុក-សំពះព្រះខែ នៅថ្ងៃពេញបូណ៌មី ខែកត្តិកនេះ ព្រោះជាពេលបំណាច់ខែវស្សាកាលផង ជាពេលសំបូរដោយ ចេក អំបុក អំពៅ ត្រាវ និងដំឡូងផង។ ចប់

"ព្រះជួយតែមនុស្សណាដែលចេះជួយខ្លួនឯង"

Thus the people celebrate the Auk Ambok and Sampeah Preah Khe ceremony on full moon day of November because it is the end of rainy season and it is the time that is rich in bananas, pounded rice, sugarcane, taro and potatoes etc... ***The end***

***"God helps those who help themselves"***